# ប្រតិមាព្រះអគ្និ (អគ្គី) នៅសម័យបុរាណ

ព្រះអគ្និ ឬហៅម្យ៉ាងទៀតថា "ព្រះអគ្គី" ជាទេពដ៏សំខាន់មួយនៅសម័យវេទ ដែលគេចាត់ទុកថាជា ព្រះតំណាងឱ្យភ្លើង និងជាលោកបាលប្រចាំនៅទិសអាគ្នេយ៍។ ព្រះអគ្គ ជាអ្នកតភ្ជាប់ (ទូត) រវាងពិភពមនុស្សនិងអាទិទេព តាមរយៈអណ្ដាតភ្លើងនៃកិច្ចបូជាយញ្ញ។ ព្រះអគ្គ ជាអ្នកនាំយកតង្វាយពីមនុស្សថ្វាយទៅដល់ព្រះហស្តរបស់របស់អាទិទេពដទៃទៀត និងជាសាក្សីនៃអំពើរបស់មនុស្ស។ ព្រមជាមួយគ្នានេះ ព្រះអគ្និ ជាអ្នកបណ្ដេញភាពងងឹត និងភាពភ័យខ្លាចនៅក្នុងពេលរាត្រី។ នៅក្នុងសង្គមខ្មែរ ទេពអគ្គនេះចាប់ផ្ដើមមានអ្នកប្រណិប័តន៍ និងមានឥទ្ធិពលដំបូងតាំងពីរវាងចុងសម័យហ្វូណន ឬដើមសម័យចេនឡា (ដើមស.វ.ទី៧)។ តាមរយៈឥទ្ធិពលនេះ បុព្វបុរសខ្មែរបានបង្កើតឱ្យមានរូបភាពសិល្បៈជា "ព្រះអគ្និ" តាមរយៈចម្លាក់ផង និងប្រតិមាផង។ តើប្រតិមាព្រះអគ្និ (ព្រះអគ្គី) នៅក្នុងសិល្បៈខ្មែរនាសម័យបុរាណ មានលក្ខណៈដូចម្ដេចខ្លះ?

នៅក្នុងព្រហ្មញ្ញសាសនា ព្រះអគ្និ ជាបុត្ររបស់មហាឫសីកស្សប និងព្រះនាងអទិតិ ដែលគេស្គាល់ថាជាព្រះមាតារបស់ទេវតាទាំងឡាយ។ យោងតាមគម្ពីរផ្សេងទៀត គេបានចាត់ទុកព្រះអគ្គជាបុត្ររបស់ព្រះព្រហ្ម (ទេពបង្កើតលោក) ឬគម្ពីរខ្លះទៀតរៀបរាប់ថា ព្រះអគ្គកើតចេញពីកិច្ចប្រឹងប្រែងនៃធាតុទាំងបី ហើយគម្ពីរខ្លះទៀតរៀបរាប់ប្រៀបធៀបថា ព្រះអគ្គកើតចេញពីមាតាចំនួន ១០ (តំណាងឱ្យម្រាមដៃទាំង១០ របស់អ្នកធ្វើយញ្ញបូជា)។ ព្រះអគ្គមានព្រះនេត្របី ព្រះហស្តបួន មានចំណីអាហារជាខ្លាញ់និងភ្លើងចម្រុះ ហើយមានយានជំនិះជាសត្វចៀម ពពែ និងជួនកាលជាសត្វរមាស។ មហេសីរបស់ព្រះអគ្និ មានព្រះនាមថា ព្រះនាងស្វាហៈ ដែលជាបុត្រីរបស់ព្រះប្រជាបតី ហើយគេស្គាល់ថាជាទេវនារីដែលគេតែងហៅឈ្មោះនៅពេលធ្វើកិច្ចបួងសួង ឬហោមពិធីនៅក្នុងពេលបញ្ជូនតង្វាយទៅដល់ព្រះអគ្និ ពោល គឺគេតែងសូត្រថា "ស្វាហៈ"។ ព្រមជាមួយគ្នានេះ គេដឹងថាព្រះស្កន្ទជាបុត្ររបស់ព្រះសិវ តែគម្ពីរខ្លះបាននិយាយថា ព្រះស្កន្ទ ក៏ជាបុត្ររបស់ព្រះអគ្និផងដែរ។ ក្រៅអំពីនេះ ទ្រង់មានបុត្រតំណាងឱ្យទម្រង់ភ្លើងផ្សេងៗទៀត ដូចជា ព្រះបាវក ព្រះសុចិ និងព្រះបវមាន។

នៅសម័យបុរាណ គេគោរពប្រតិបត្តិចំពោះព្រះអគ្និខ្លាំងណាស់ ដោយសារតែទ្រង់ប្រៀបដូចជារាជទូត ឬអ្នកនាំសាររបស់មនុស្សថ្វាយចំពោះទេព ឬជាសាក្សីរបស់អំពើរបស់មនុស្ស។ ក្នុង

*នោះ សិលាចារឹកមួយផ្ទាំងនៅក្នុងរាជ្យព្រះបាទស្រីជ័យវរ្ម័នទី៧ បានបញ្ជាក់ឱ្យដឹងថា ព្រះអគ្និគង់នៅលើសត្វរមាស ដែលប្លែកពីវប្បធម៌ដទៃទៀតដែលភាគច្រើនបង្ហាញព្រះអង្គគង់នៅលើសត្វចៀម ឬពពែតែប៉ុណ្ណោះ។ វត្តមានរបស់ព្រះអគ្និ ភាគច្រើនបង្ហាញនៅលើចម្លាក់ប៉ុណ្ណោះ ហើយមានតិចណាស់ដែលគេប្រតិស្ឋានរូបព្រះអគ្និជាប្រតិមាទោល។ ជាក់ស្ដែង មានចម្លាក់ព្រះអគ្និជាច្រើននៅលើចម្លាក់ផ្ទាំងថ្មទេពប្រាំបួន (ខ្លះហៅថាទេពនព្វគ្រោះ) ដែលភាគច្រើនគេបង្ហាញព្រះអង្គគង់នៅលេខរៀងទី៧ ជាប់នឹងរាហូ។ ក្នុងនោះ ចម្លាក់ព្រះអង្គគង់នៅលើសត្វរមាសនៃចម្លាក់ទេពប្រាំបួន រកឃើញតែមួយប៉ុណ្ណោះ គឺនៅប្រាសាទនាងខ្មៅ រីឯរូបផ្សេងទៀតបង្ហាញព្រះអង្គគង់នៅលើសត្វពពែ ដូចជា ប្រាសាទលលៃ ប្រាសាទគុករកា ។ល។ រីឯ ចម្លាក់ព្រះអគ្និគង់នៅលើសត្វរមាសបង្ហាញនៅលើជញ្ជាំងប្រាសាទ ឃើញនៅប្រាសាទអង្គរវត្ត និងប្រាសាទបឹងមាលា។ នៅលើចម្លាក់ទេពប្រាំបួន គេច្រើនបង្ហាញព្រះអគ្និកាន់ដំបង និងកូនកាំបិតខ្វី។*

*ដោយឡែក ការបង្ហាញព្រះអគ្និជាទម្រង់ប្រតិមាទោល មានភាពកម្រខ្លាំងណាស់។ ក្នុងនោះ នៅសម័យដំបូង (រវាងស.វ.ទី៧) គេប្រទះឃើញប្រតិមាព្រះអគ្និតែមួយអង្គប៉ុណ្ណោះ (ធ្វើអំពីថ្មភក់) ដែលរកឃើញតាមរយៈបេសកកម្មរបស់លោក* Étienne Aymonier *ក្នុងឆ្នាំ១៨៨២-១៨៨៣ ពោល គឺលោកបានប្រទះឃើញនៅវត្តមួយក្នុងស្រុកអង្គរបុរី ខេត្តតាកែវ (អតីតកាលជាស្រុកព្រៃកប្បាស)។ នៅក្នុងឆ្នាំ១៨៩០ លោក* Aymonier *បានបញ្ជូនប្រតិមានេះមកកាន់សារមន្ទីរជាតិហ្គីមេត ប្រទេសបារាំង។ នៅពេលរកឃើញដំបូង គេមិនស្គាល់ថាប្រតិមានេះជាព្រះអគ្និនោះឡើយ ហើយលោក* Aymonier *គ្រាន់តែហៅរូបនេះថា "**ទេវតាគង់នៅលើសត្វជ្រូក**" តែប៉ុណ្ណោះ។ រហូតមកដល់ឆ្នាំ១៩៣១ គេបានយកប្រតិមានេះទៅដាក់តាំងពិព័រណ៍ តែគេបែរជាហៅប្រតិមានេះថា "ព្រះសិវគង់នៅលើសត្វគោនន្ទិ" ទៅវិញ ទោះបីជាសត្វជាយានជំនិះនៅខាងក្រោមទេពមិនដូចសត្វគោនន្ទិក៏ដោយក្ដី។ អ្នកស្រាវជ្រាវក្រោយមកទៀត យល់ឃើញថា សត្វដែលព្រះអង្គគង់នៅលើនោះ មិនមែនជាសត្វគោទេ ព្រោះរូបរាងវាចម្លែក មានច្រមុះធំ និងមានកម្រាលកែបអង្កាញ់នៅលើខ្នង។ ក្រោយមកទៀត លោក* Pierre Baptiste *និងលោក* Thierry Zéphir *យល់ឃើញថា ប្រតិមាទេវរូបនេះ គឺជាព្រះអគ្និគង់នៅលើសត្វរមាស ដោយបានសិក្សាប្រៀបធៀបជាមួយចម្លាក់សត្វរមាសដែលរកឃើញនៅលើបល្ល័ង្កតង្វាយប្រភេទបលិបីឋនៅក្នុងសិល្បៈចាម្ប៉ា ដែលរក្សាទុកនៅសារមន្ទីរខេត្ត* Thừa Thiên Huế *និងមកពី* Vân Trạch Hòa។ *ប្រតិមាព្រះអគ្និមួយអង្គនេះ មានកម្ពស់ ៣៨ស.ម. ទទឹង ១៩ស.ម. ដែលបង្ហាញក្នុងទម្រង់ជាទេវរូបវ័យក្មេងកំពុងអង្គុយស្រដៀងទម្រង់មហារាជលីលសន ក្នុងព្រះភក្ត្រញញឹមស្ញប់ តែព្រះហស្តស្ដាំបានបាក់បែក*

មួយកំណាត់ ព្រះហស្តឆ្វេងដាក់នៅលើក្បាលជង្គង់ និងគ្មានគ្រឿងអលង្ការសម្គាល់ច្បាស់លាស់ឡើយ។ ព្រះកេសប្រតិមានេះ រចនាឡើងយ៉ាងប្លែក ដោយប្រមូលផ្តុំជាក្តួចរួញរាងអឌ្ឍគោលលើព្រះសិរ ដែលមានលក្ខណៈស្រដៀងនឹងពួកអសុរ ឬយក្ស។ លោក Pierre Baptiste និងលោក Thierry Zéphir យល់ឃើញថា សាច់ដុំដ៏រឹងមាំ ខ្ទីៗ និងព្រះហស្តធាត់ៗដែលបង្ហាញនៅលើប្រតិមាអង្គនេះ គឺមានលក្ខណៈស្រដៀងស្នាដៃសិល្បៈមួយចំនួនដែលរកឃើញនៅតំបន់ដីសណ្តទន្លេមេគង្គ និងជាប់ពាក់ព័ន្ធជាមួយវប្បធម៌អូរកែវ ហើយភាគច្រើនប្រតិមាទាំងនោះជារូបព្រះវិស្ណុ។ ទន្ទឹមនេះ សមាមាត្រនៃព្រះសិរប្រតិមាអង្គនេះ មានលក្ខណៈដូចគ្នាច្រើនទៅនឹងសិល្បៈរចនាបថភ្នំដា (ចុងស.វ.ទី៦ ឬដើមស.វ.ទី៧)។ លើសពីនេះទៅទៀត ប្រតិមានេះមានលក្ខណៈសិល្បៈជាច្រើនស្រដៀងសិល្បៈចាម្ប៉ា នៅក្នុងរចនាបថ My Son E1 ដូចជា៖ (១). ព្រះភក្ត្រស្រដៀងចម្លាក់រូបមនុស្សនៅតំបន់ My Son E1, (២). ព្រះកេសរួញៗរាងទូលាយនិងមានស្នាមធ្លាក់បញ្ឈរ ស្រដៀងព្រះកេសចម្លាក់នៅចាម្ប៉ា និង (៣). ចម្លាក់សត្វរមាសដែលជាយានជំនិះព្រះអគ្និ ស្រដៀងសត្វរមាសនៅលើបល្ល័ង្កតង្វាយប្រភេទបលិបីឋ មកពីខេត្ត Thừa Thiên Huế និង Vân Trạch។

មកដល់សម័យអង្គរ ព្រះអគ្និបង្ហាញជាទម្រង់ប្រតិមាទោល ក៏កម្រមានដូចគ្នា ជាពិសេសគឺប្រតិមាព្រះអគ្និធ្វើអំពីថ្មភក់ តែចម្លាក់មានច្រើនណាស់ ដូចបានរៀបរាប់ខាងលើ។ ទោះជាយ៉ាងនេះក្តី គេបានប្រទះឃើញប្រតិមាព្រះអគ្និមួយអង្គសាងអំពីសំរិទ្ធ ដែលទំនងសាងឡើងនៅសម័យអង្គរ។ ប្រតិមានេះ កំពុងដាក់តាំងបង្ហាញក្នុងទូកញ្ចក់នៅសារមន្ទីរជាតិកម្ពុជា ដែលមានកម្ពស់ ១៧,៥ស.ម., ទទឹង ៧ស.ម., កម្រាស់ ៨,៨ស.ម. និងទម្ងន់ ០,៦៧គ.ក. ហើយបង្ហាញឡើងក្នុងទម្រង់អង្គុយនៅលើសត្វពពែជាយានជំនិះ (ខាងក្រោមសត្វពពែទ្រដោយជើងទម្ររាងមូល)។ គេអាចមើលប្រតិមានេះស្គាល់ថាជាព្រះអគ្និ ក៏ដោយសារតែសត្វពពែជាយានជំនិះនេះតែម្តង ដែលលក្ខណៈរបៀបនេះគេធ្លាប់ឃើញច្រើននៅតាមផ្ទាំងចម្លាក់ទេពប្រាំបួន (លេខរៀងទី៧)។

សរុបជារួមមក ប្រតិមាព្រះអគ្និ (ព្រះអគ្គី) ការបង្ហាញព្រះអគ្គិជាទម្រង់ប្រតិមាទោលមានភាពកម្រណាស់ ប៉ុន្តែបុព្វបុរសខ្មែរបានបន្សល់ទុកនូវវត្ថុតាងដ៏មានតម្លៃ ដូចជាប្រតិមាថ្មភក់សម័យមុនអង្គររកឃើញនៅស្រុកអង្គរបុរី ខេត្តតាកែវ និងប្រតិមាសំរិទ្ធសម័យអង្គរ(មិនស្គាល់ប្រភព) ដែលតម្កល់នៅសារមន្ទីរជាតិកម្ពុជា។ វត្តមាននៃប្រតិមាព្រះអគ្និទាំងនេះ មិនត្រឹមតែបង្ហាញឱ្យឃើញពីជំនឿសាសនា និងការទទួលយកឥទ្ធិពលវប្បធម៌ឥណ្ឌាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញពីភាពច្នៃប្រតិដ្ឋដ៏សម្បូណ៌បែបនៃសិល្បៈខ្មែរ ក្នុងការបង្កើតរូបភាពតំណាងឱ្យទេពដោយភ្ជាប់ទាំងសត្វជាយានជំនិះ ពោល គឺមានទាំងសត្វរមាស និងពពែ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## បញ្ជីឯកសារពិគ្រោះ


Aymonier, É. (1900). *Le Cambodge: Le groupe d'Angkor et l'histoire*. Paris: Ernest Leroux.

Baptiste, P. and Zéphir, T. (eds.) (2005). *L'art khmer dans les collections du musée Guimet*. Paris: Éditions de la Réunion des musées nationaux.

Bhattacharya, K. (1961). *Les religions brahmaniques dans l'ancien Cambodge, d'après l'épigraphie et l'iconographie*. Paris: École Française d'Extrême-Orient.

Bénisti, M. (1976). Notes d'iconographie khmère XI. *Bulletin de l'École française d'Extrême-Orient*, 63, pp. 375–388. https://doi.org/10.3406/befeo.1976.3893

Chhum, M. (2020). Nine Deities Panel in Ancient Cambodia, in *Pratu: Journal of Buddhist and Hindu Art, Architecture and Archaeology of Ancient to Premodern Southeast Asia*, 1(2), 1-17. https://doi.org/10.25501/SOAS.00032560

Chronique (1931). Chronique: Cambodge. *Bulletin de l'École française d'Extrême-Orient (BEFEO)*, 31(3/4), p. 648, no. 98.

Macdonell, A.A. (1974). *Vedic Mythology*. Varanasi: Indological Book House.

Malleret, L. (1960). Contribution a l'étude du thème des Neuf Divinités dans la sculpture du Cambodge et du Champa. *Arts Asiatiques*, 7(3), pp. 205–230

Mauger, H. (1935). *Notes and Field Records on Angkor Borei Excavations* (Unpublished archival notes, dated 31 May 1935). Paris: École Française d'Extrême-Orient.
Roveda, V. (2005). *Images of the Gods: Khmer Mythology in Cambodia, Thailand and Laos*. Bangkok: River Books.

Stutley, M. (2003). *The Illustrated Dictionary of Hindu Iconography*. New Delhi: Munshiram Manoharlal.

Wessels-Mevissen, C. (2001). *The Gods of the Directions in Ancient India: Origin and Early Development in Art and Literature (until c.1000 A.D.)*. Berlin: Dietrich Reimer Verlag



រូបលេខ១៖ ប្រតិមាព្រះអគ្និ សាង់ពីថ្មភក់ រកឃើញនៅស្រុកអង្គរបុរី ខេត្តតាកែវ (ស.វ.ទី៧?) (មើលចំពីមុខ)
ប្រភពរូប៖ Pigalle

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ ប្រតិមាព្រះអគ្និ សាងពីថ្មភក់ រកឃើញនៅស្រុកអង្គរបុរី ខេត្តតាកែវ (ស.វ.ទី៧?) (មើលពីចំហៀង)
ប្រភពរូប៖ សារមន្ទីរជាតិហ្គីមេត

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៣-៤៖ ប្រតិមាព្រះអគ្និ សាងពីសំរឹទ្ធ មិនស្គាល់ប្រភព (សម័យអង្គរ?) (មើលពីមុខ និងចំហៀង)
ប្រភពរូបលេខ៣៖ សារមន្ទីរជាតិកម្ពុជា



រូបលេខ៥៖ លម្អិតប្រតិមាព្រះអគ្និ សាងពីសំរឹទ្ធ មិនស្គាល់ប្រភព (សម័យអង្គរ?) (មើលពីចំហៀង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី